# សាច់រឿង ផ្នែកទី ២

បន្ទាប់ពីមេរៀនថ្នាក់វិទ្យាស្ថានស្ដីពីអាពាហ៍ពិពាហ៍ដ៏នៅអស់កល្បជានិច្ច ទាំង លូអ៊ីស និង អិមម៉ា មានអារម្មណ៍ចង់ធ្វើការផ្លាស់ប្តូរមួយចំនួន ហើយទុកចិត្តទៅលើព្រះអម្ចាស់កាន់តែខ្លាំងឡើង ។ នៅពេល លូអ៊ីស មកដល់ថ្នាក់វិទ្យាស្ថាននៅសប្តាហ៍ក្រោយ គាត់ទៅអង្គុយជិត អិមម៉ា ហើយណែនាំខ្លួនគាត់ ។ យូរៗទៅ ពួកគេក្លាយជាមិត្តល្អនឹងគ្នា ។ ពួកគេដាក់ផែនការធ្វើសកម្មភាពជាច្រើន ដែលអនុញ្ញាតឲ្យពួកគេចំណាយពេលជាមួយគ្នា និងរៀនអំពីគ្នាទៅវិញទៅមក ។ មិនយូរប៉ុន្មានពួកគេមានអារម្មណ៍កាន់តែជិតដិតនឹងគ្នា ។

ប៉ុន្តែ អិមម៉ា មានកង្វល់មួយចំនួន ។ នាងមានបញ្ជីគុណសម្បត្តិមួយ ដែលនាងចង់ឲ្យស្វាមីម្នាក់មាន ។ លូអ៊ីស មានគុណសម្បត្តិទាំងនេះជាច្រើន ប៉ុន្តែមិនមែនទាំងអស់នោះទេ ។

លូអ៊ីស ក៏ចាប់ផ្តើមមានអារម្មណ៍ភ័យដែរ ។ គាត់ស្រឡាញ់អិមម៉ា ប៉ុន្តែដោយបានឃើញអាពាហ៍ពិពាហ៍របស់ឪពុកម្ដាយគាត់ផ្ទាល់បែកបាក់ នោះគាត់ខ្លាចថានឹងមានកំហុស ក្នុងការជ្រើសរើសមនុស្សដែលត្រូវរៀបការជាមួយ ។ គាត់ពិចារណាដោយប្រុងប្រយ័ត្នពីអ្វីៗគ្រប់យ៉ាង ដែលគាត់បានដឹងអំពីអិមម៉ា ចេញមកពីការសន្ទនាជាច្រើនរបស់ពួកគេ និងបទពិសោធន៍ជាមួយគ្នា ។ គាត់មានអារម្មណ៍ថា គោលដៅរបស់ពួកគេដូចគ្នា ហើយចង់សុំអិមម៉ាឲ្យរៀបការនឹងគាត់ ប៉ុន្តែវានៅតែមានកត្តាជាច្រើនដែលគាត់មិនដឹង ។ លូអ៊ីស អធិស្ឋានសូមទីសម្គាល់មួយដែលបញ្ជាក់ថា អិមម៉ាគឺជាជម្រើសដ៏ត្រឹមត្រូវ ។ តែគ្មានអ្វីកើតឡើងនោះទេកន្លងមកនេះ ។

- សូមពិចារណាពីអ្វីដែលអ្នកបានរៀនមកពី ផ្នែកទី ២ នៃឯកសាររៀបចំ ។ តើមានអ្វីដែលអាចជួយ អិមម៉ា ទាក់ទងទៅនឹងបញ្ជីស្វែងរកអនាគតស្វាមីរបស់នាង ? តើយើងអាចប្រឈមមុខនឹងបញ្ហាអ្វីខ្លះ ប្រសិនបើការរំពឹងទុករបស់យើងអំពីអនាគតស្វាមី ឬភរិយាទាបពេក ឬខ្ពស់ពេកនោះ ?
- តើមានអ្វីខ្លះដែលមានប្រយោជន៍ ដែលលូអ៊ីសត្រូវយល់អំពីការភ័យខ្លាចរបស់គាត់ ? តើមានអ្វីខ្លះដែលមានប្រយោជន៍ ដែលគាត់ត្រូវយល់អំពីការទទួលបានវិវរណៈ ?
  ( អ្នកអាចពិនិត្យ ផ្នែកទី ៣ នៃឯកសាររៀបចំ ឡើងវិញបាន ) ។
- តើមានសកម្មភាព ឬបទពិសោធន៍អ្វីខ្លះ ដែលអាចជួយបុគ្គលទាំងពីររូបនេះឲ្យបង្កើតចំណងមិត្តភាព ហើយរៀនស្គាល់គុណសម្បត្តិ អត្តចរិត និងគុណតម្លៃរបស់គ្នាទៅវិញទៅមកបានកាន់តែច្បាស់នោះ ? តើអ្វីទៅជាគុណសម្បត្តិរបស់ព្រះអង្គសង្គ្រោះមួយ ឬពីរ ដែលអ្នកសង្ឃឹមថានឹងអភិវឌ្ឍឲ្យបាន ដើម្បីរៀបចំខ្លួនសម្រាប់អាពាហ៍ពិពាហ៍ ឬនៅពេលអ្នកបន្តនៅក្នុងអាពាហ៍ពិពាហ៍ ?

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© ២០២២ by Intellectual Reserve, Inc. All rights reserved.